ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ..........................................................

# សេចក្តីប្រកាសព័ត៌មាន

ចាប់ពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជានឹងដំណើរការ "ប្រព័ន្ធផាត់ទាត់ជាតិ" (National Clearing System) ជាផ្លូវការ ដើម្បីបង្កើនប្រសិទ្ធភាព និងពង្រីកការផ្តល់សេវាផាត់ទាត់ និងទូទាត់សម្រាប់ការទូទាត់អន្តរធនាគារនៅកម្ពុជា តាមរយៈប្រព័ន្ធផាត់ទាត់ជាតិថ្មីនេះ ។

ប្រព័ន្ធផាត់ទាត់ជាតិដែលដាក់ដំណើរការនេះអាចផាត់ទាត់ និងទូទាត់ឧបករណ៍ទូទាត់ ដូចជា មូលប្បទានបត្រ និងបញ្ជាទូទាត់ជាអេឡិចត្រូនិកដែលបង្កើតស្របច្បាប់ (ការផ្ទេរឥណទាន ឥណទានផ្ទាល់ និងឥណពន្ធផ្ទាល់) ជាលក្ខណៈមជ្ឈការ នៅសភាផាត់ទាត់ជាតិ (National Clearing House) ពោលគឺ ការផាត់ទាត់និងទូទាត់ឧបករណ៍ទាំងនេះអាចបញ្ចប់នៅក្នុងថ្ងៃ និងប្រព្រឹត្តទៅនៅសភាផាត់ទាត់ជាតិដែលមានទីតាំងនៅធនាគារជាតិនៃកម្ពុជា ។ ដូច្នេះ ធនាគារអាចធ្វើការផ្ទេរប្រាក់អតិថិជនរបស់ធនាគារមួយទៅអតិថិជនរបស់ធនាគារមួយផ្សេងទៀតនៅក្នុងថ្ងៃដដែល គ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា ។

ធនាគារជាតិនៃកម្ពុជាបានដំណើរការអភិវឌ្ឍប្រព័ន្ធផាត់ទាត់ជាតិនេះដោយបានប្រើរយៈពេលជាច្រើនឆ្នាំ ក្រោមការឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា និងដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ។ ប្រព័ន្ធផាត់ទាត់ជាតិនេះត្រូវបានរៀបចំឡើងដោយបានប្រើប្រាស់បច្ចេកវិទ្យាសុវត្ថិភាព និងទំនើបដែលមានចុងក្រោយ ដើម្បីធានាសុវត្ថិភាពនិងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាផាត់ទាត់និងទូទាត់អន្តរធនាគារ ។

ការអភិវឌ្ឍប្រព័ន្ធនេះ ជាផ្នែកមួយដ៏ធំនៃការអនុវត្តតាមទិសដៅរយៈពេលវែងរបស់ធនាគារជាតិនៃកម្ពុជាដែលមានចែងនៅក្នុងឯកសារ "យុទ្ធសាស្ត្រនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ២០១១-២០២០" របស់រាជរដ្ឋាភិបាល ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ចកម្ពុជាដែលកំពុងមានការអភិវឌ្ឍយ៉ាងលឿន និងតម្រូវការទូទាត់ឧបករណ៍ទូទាត់ផ្សេងៗដែលកាន់តែមានការប្រើប្រាស់ច្រើនឡើង ។

ធនាគារជាតិនៃកម្ពុជារំពឹងថា ធនាគារនឹងប្រើប្រាស់ប្រព័ន្ធថ្មីនេះដើម្បីពង្រីកការផ្តល់សេវាទូទាត់ឲ្យកាន់តែមានប្រសិទ្ធភាព ជូនអតិថិជនរបស់ខ្លួន ។ល

ភ្នំពេញ, ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២